# អត្ថាធិប្បាយ

# ហ៊ុន_សែនការពារស្ដេច !!

## Le Joueur d'échecs

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១១ វិច្ឆិកា ២០០៥

នរណាក៏ដឹងដែរថា ហ៊ុន-សែនជាអ្នកជំនាញខាងល្បែងអុក... ប្រទេសកម្ពុជាក៏ជាក្រឡាអុក ចំណែកស្ដេចសីហនុគឺជា «ស្ដេចអុក» របស់ហ៊ុន-សែន ។ ក្នុងប្រការនេះហ៊ុន-សែនមិនអាចបណ្ដោយឲ្យបរបក្សរបស់ខ្លួនស៊ី«ស្ដេច»បានទេ ។ លោកលី-ឌៀបបានសរសេរជាច្រើនដងច្រើនសាណាស់ថា ៖ «ស្ដេចសីហនុនៅតែគាំទ្រហ៊ុន-សែន ចំណែកហ៊ុន-សែននៅតែគាំទ្រស្ដេចសីហនុ»... ប៉ុន្តែអ្នកផងមិនព្រមជឿរឿងនេះទេ ។ ទើបតែឥឡូវនេះ ទើបយើងមើលឃើញយ៉ាងច្បាស់ពន់ពេកថា ស្ដេចសីហនុហើយនិងហ៊ុន-សែន មានចៅហ្វាយតែមួយ ៖ គឺមហាប្រទេសចិន ។ ម្លោះហើយអ្នកទាំងពីរមិនអាចបែកបាក់គ្នា ដោយពិតប្រាកដបានទេ ៖ វិវាទជម្លោះរវាងស្ដេចសីហនុ (អ្នកលក់ដីឲ្យយួន) ហើយនិងហ៊ុន-សែន (អាយ៉ងយួន) អំពីប-ញ្ហាព្រំដែន គឺគ្រាន់តែជាការសំដែងល្ខោនរបស់ហ៊ុន-សែន ដើម្បីទាក់-កពួកអ្នកបំរើស្ដេច ទាំងខាងក្រៅនិងខាងក្នុង ទៅសណ្ដូនថ្នូទម្លាក់ទឹកតែប៉ុណ្ណោះ ។ តែចំពោះបុគ្គលសីហនុវិញ... ហ៊ុន-សែននៅតែលើកតម្កើងទ្រង់ជា «មហាវីរក្សត្រ» ជារៀងរហូត !

គ្រាន់តែហ៊ុន-សែនយកចំរៀង «អធិរាជសម្លេងមាស» ស៊ិន-ស៊ីសាមុតយកមកចាក់ផ្សាយអំពី «ស្ដេចសីហនុលក់ដីឲ្យយៀកកុង», ក៏ស្រាប់តែអ្នកបំរើស្ដេចទាំ-ងអម្បាលមាណ ទាំងខាងក្រៅនិងទាំងខាងក្នុង ក្លាយទៅជាសត្វបង្គួយប្រែពណ៌ ។

<u>ទី១- អ្នកឲ្យទឹកស្ដេចទៅពីខាងក្រៅ</u> ៖

សម-រង្ស៊ីស្រាប់តែប្រែពណ៌ទៅជា«សម-សារី» ។ លោកស៊ាន-ប៉េងសែស្រាប់តែប្រែពណ៌ទៅជា«យួន» ។ ស៊ីសុវត្ថិ-ធម្មិកោ ប្រែពណ៌ទៅជាអ្នកម្នាងម៉ូនិកគឺយួនដូចគ្នា ពោលគឺក្រុមទេវតាទាំងអស់ បានប្រែកាឡាខ្លួនទៅជាព្រាយបិសាច ។

ចំណែកពួកក្រុមសាធារណរដ្ឋ ដែលកំពុងតែបំរើស្ដេចក្នុងរដ្ឋាភិបាលហ៊ុន-សែនសព្វថ្ងៃ កំពុងតែភ័យញ័រសាច់ ពីព្រោះពួកគេកំពុងតែប្រែពណ៌ទៅជា«ជនក្បត់ស្ដេច» មានជាអាទិ លោកលូ-ឡាយស្រេង, ប៉ុក-ថន, កុល-ផេង, ហេង-វង្សប៊ុ

នឆាត,ឃី-តាំងលឹម, ហ៊ុយ-កន្ធលវ៉ា ។ ពួកអ្នកទាំងនេះបានក្លាយទៅជា «ចំណាប់ខ្មាំង», ជាពួកត្រីជាប់ជុច ជាពួកឆ្កែបំរើជាប់ថ្លៃរបស់ហ៊ុន-សែន... ពោលគឺជាពួកខ្ញុំកញ្ជះរបស់អាយ៉ងយួន (គឺជាពួកមានកំណើតយួន) ។ មិនគឺហ៊ុន-សែនទេឬដែលធ្លាប់បានពោលថា ៖ «ឆ្កែខ្ញុំចេះនិយាយភាសាអង់គ្លេស !»...។ តើពួកឆ្កែចេះអង់គ្លេសមាននរណាក្រៅពីពួកខាងលើនេះ ? ។

<u>ទី២- អ្នកឲ្យទឹកស្តេចនៅពីខាងក្នុងបក្សប្រជាជន</u> ៖

តាមពិតហ៊ុន-សែនមិនដែលព្រឺស្មៀបនឹងពួក «តាជុះ» ឬពួកចាក់ខ្សែប្រកបដោយឧត្តមគតិឆ្គេឆ្គា ដែលនៅពីខាងក្រៅនោះទេ, ក៏ប៉ុន្តែហ៊ុន-សែនតែងមានការព្រួយបារម្ភជានិច្ច អំពីការបះបោរ ឬការឃុបឃិតក្បត់ «ចូលស្តេច» នៅក្នុង«បក្សប្រជាជន» ។ ក៏ប៉ុន្តែនៅក្នុងពេលឥឡូវនេះវិញ សូម្បីតែពួកមេដឹកនាំដ៏សំខាន់ៗរបស់គណបក្ស«ប្រជាជន» ក៏ត្រូវហ៊ុន-សែនចងក្រៀកជាប់ដូចសត្វក្រពើ ដែលគេបំរុងយកទៅពន្លាត់ស្បែកដូច្នោះឯង ។

នៅថ្ងៃទី១៧តុលាឆ្នាំ២០០៥ លោកហ៊ុន-សែនបានថ្លែងនៅក្នុងទូរទស្សន៍កម្ពុជា (Source: BBC Monitoring of Television Kampuchea, October 17, 2005) នូវពាក្យចោទប្រកាន់ទៅលើក្រុមមេដឹកនាំបក្សប្រជាជន ដែលមានសេចក្តីជាអាទិដូច្នេះថា ៖ «...ខ្ញុំបានអត់ទ្រាំយូរពេកណាស់មកហើយ ។ ខ្ញុំមិនអាចអត់ទ្រាំឲ្យលើសពីនេះបានទៀតទេ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំអត់ទ្រាំបានតែត្រឹមព្រំដែននៃច្បាប់អនុញ្ញាតតែប៉ុណ្ណោះ ។ បើខ្ញុំមិនគោរពច្បាប់, កងទ័ពនៅក្នុងដៃខ្ញុំស្រាប់ គ្មាននរណាម្នាក់អាចប្រឆាំងខ្ញុំបានទេ ។ ប្រសិនបើកែ-គឹមយ៉ាន (អគ្គមេបញ្ជាការកងទ័ព) មិនធ្វើតាម... ខ្ញុំនឹងប្រគល់ឲ្យគន់-គីម (មេទ័ពម្នាក់ជិតស្និទ្ធជាមួយនឹងហ៊ុន-សែន) <u>ធ្វើជំនួស</u> (<u>កកន</u> ៖ សំដីនេះ គឺការគំរាមកំហែងចាប់ចងជា-ស៊ីម ។ តែគឺជាការវាយផ្លែឲ្យពួកហុក-ឡងឌីផងដែរ ពីព្រោះកាលពីឆ្នាំទៅ ហ៊ុន-សែនបានបញ្ជាឲ្យហុក-ឡងឌីចាប់ខ្លួនជា-ស៊ីម, ក៏ប៉ុន្តែហុក-ឡងឌីបែរទៅជាពង្រត់ជា-ស៊ីមទៅប្រទេសថៃ) ។

នៅក្នុងទូរទស្សន៍ដដែល ហ៊ុន-សែនបានបន្តសេចក្តីដូច្នេះទៀតថា ៖ «ប៉ុន្តែកែ-គឹមយ៉ានត្រូវធ្វើតាមបញ្ជា... បើពុំដូច្នោះទេ គាត់នេះត្រូវដកចេញ ។ កុំថាឡើយគាត់ឯងជាឧត្តមសេនិយផ្កាយ៤ សូម្បីគាត់ឯងមានព្រះចន្ទនៅលើស្មា ក៏ត្រូវតែដកចេញដែរ ។ ខ្ញុំមិនមែនដូចសម្តេចព្រះនរោត្តម-សីហនុនោះទេ ។ សម្តេចព្រះនរោត្តម-សីហនុ ចូលចិត្តប្រើអ្នកដទៃឲ្យធ្វើរដ្ឋប្រហារ ។ ខ្ញុំមិនអញ្ចឹងទេ ។ កុំសាកល្បងលេងល្បែងនេះឲ្យសោះ ។ អ្នកឯងធ្វើ...អ្នកឯងងាប់ ។ ខ្ញុំសូមព្រមានជាមុនឲ្យហើយ ។ ហើយខ្ញុំសូមប្រាប់ទៅជនម្នាក់ ដែលបានប្រកាសអំពាវនាវនៅចុងឆ្នាំ១៩៩៣ (ប្តូរកំនិត) ឆ្នាំ២០០៣ ស្នើឲ្យកងទ័ពភ្ជង់អាវុធទៅលើរដ្ឋាភិបាល ។ ត្រូវចាត់ទុកថា អ្នកឯងសំណាងហើយ... សំណាងធំហើយដែលហ៊ុន-សែនមិនបានប្តឹងអ្នកឯងពី

កាលនោះ ។ ហេតុអ្វី ? ហ៊ុន-សែនចង់ដឹងថា តើការអំពាវនាវរបស់អ្នកឯង មានមនុស្សយកចិត្តទុកដាក់ស្តាប់ឬទេ ? បើមានមនុស្សឆ្លើយតបតចំពោះការអំពាវនាវរបស់អ្នកឯង មានតែ៥នាក់លើកកាំភ្លើងបាញ់ទៅលើហ៊ុន-សែន, នោះអ្នកឯងត្រូវស្លាប់ ។ ខ្ញុំចង់ប្រាប់អ្នកឯងឲ្យហើយអំពីរឿងនេះ ។ ខ្ញុំមិនបានប្តឹងអ្នកឯងពីរឿងនេះ ពីព្រោះហ៊ុន-សែនចង់ឃើញកម្លាំងពិតប្រាកដរបស់អ្នកឯង ។ ឥឡូវវាហួសពេលប្តឹងទៅហើយ, លោកប្រធានស្ទីគេនោះ ។ (<u>កកន</u> ៖ «លោកប្រធានស្ទីគេនោះ» គឺប្រធាននៃគណបក្ស«ប្រជាជន» គឺជា-ស៊ីម ។ គឺជា-ស៊ីមនេះហើយ ដែលមានលទ្ធភាពបញ្ជាឲ្យកងទ័ពព្រលុំរដ្ឋាភិបាល ពីព្រោះពេលនោះគាត់មានឋានៈជាប្រមុខរដ្ឋស្តីទី) ។

«ខ្ញុំមិនបញ្ចេញឈ្មោះលោកទេ (ហ៊ុន-សែនបន្ត), ក៏ប៉ុន្តែសូមកុំប្រើភាសានេះម្តងទៀត ។ ប្រើភាសាស្រែកហៅកងទ័ពឲ្យងើបឡើងប្រឆាំងនឹងរដ្ឋាភិបាល មិនត្រូវការឆ្លងកាត់តាមរយៈតុលាការទេ, អ្នកឯងនឹងត្រូវចាប់ខ្លួន នៅទីលំនៅខ្លួនឯងតែម្តង ។ យើងត្រូវចាប់ខ្លួនអ្នកឯងសិន រួចសឹមមានការជជែកវែកញែកជាក្រោយនៅតុលាការ ។ រឿងនេះជាឧក្រិដ្ឋកម្មនៃការធ្វើរដ្ឋប្រហារ មិនមែនគ្រាន់តែជាការញុះញង់តែប៉ុណ្ណោះទេ ។ គឺជាឧក្រិដ្ឋកម្មនៃការបញ្ជាឲ្យមានរដ្ឋប្រហារ ។ អ្នកឯងនឹងត្រូវចាប់ខ្លួននៅផ្ទះអ្នកឯងតែម្តង ។ ត្រូវនិយាយរឿងនេះឲ្យច្បាស់ តែម្តងផបានចប់» ។

ពាក្យចោទប្រកាន់របស់ហ៊ុន-សែន គឺជាភាសារបស់មនុស្សឈ្នះ... ឈ្នះតាមផ្លូវចុងអាវុធផង ឈ្នះតាមផ្លូវច្បាប់ថែមទៀត ។ ពីព្រោះតាំងពីឆ្នាំ១៩៩៣មក មានការឃុបឃិតធ្វើរដ្ឋប្រហារ ប្រឆាំងនឹងរដ្ឋធម្មនុញ្ញ (ផ្តួលព្រលុំរដ្ឋាភិបាល ដើម្បីថ្វាយអំណាចគ្រប់ប្រភេទទៅស្តេច)... ប៉ុន្តែក្នុងប្រការនេះ ហ៊ុន-សែនបានកំចាត់មារសត្រូវ គ្មាននៅសល់ម្នាក់ ។ ចំពោះ«ខ្មាំងយួន» បង្កប់ខ្លួនក្នុង«បក្សប្រជាជន»...ហ៊ុន-សែនបានចង្អុលមនុស្ស៥នាក់ («មានតែ៥នាក់ងើបឡើងបាញ់ហ៊ុន-សែន គឺគាត់ឯងស្លាប់»)... ជនទាំងនេះគឺ ៖ ជា-ស៊ីម, ហេង-សំរិន, កែ-គឹមយ៉ាន, ស-ខេង, ហុក-ឡងឌី...។ ចំពោះជនទាំងនេះ ហ៊ុន-សែនបានយកចុងអាវុធ ភ្ជង់ត្រង់គុម្ពស្លឹកត្រចៀករួចស្រេចទៅហើយ... បើពួកគេមិនរើ នឹងច្បាស់ជាស្លាប់ ប៉ុន្តែបើពួកគេប្រញាប់រើបំរះ ក៏គង់តែឆាប់ស្លាប់ដូចគ្នា ។ នៅជាន់ខ្លៀករបស់ជា-ស៊ីម មានញឹក-ប៊ុនឆៃ... នៅជាប់ខ្លៀករបស់កែ-គិមយ៉ាន មានសេរី-កុសល ! ក្នុងប្រការហុក-ឡងឌីវិញ មានឧត្តមសេនិយក្នុងបក្សប្រជាជនម្នាក់ (ប្អូនថ្លៃរបស់ស៊ិន-សុង) ដែលបានរត់ចូលស្តេច ហើយខ្ចាត់មកបើកតាក់ស៊ីនៅឡុងប៊ិច បានពោលប្រាប់ខ្ញុំថា ៖ «ហុក-ឡងឌីមានតែឈ្មោះជាមេប៉ូលិសប៉ុណ្ណោះ... ប៉ុន្តែអំណាចគន្លិះរបស់ក្រសួងប៉ូលិសធ្លាក់ទៅក្នុងកណ្តាប់ដៃពួកកូនចៅខ្មែរក្រហមរបស់ហ៊ុន-សែនទាំងអស់» ។

❑

អតីតប្រធានាធិបតីចិន ម៉ៅ-សេទុងបានថ្លែងថា ៖ «សង្គ្រាមគឺជានយោបាយក្តៅ... ចំណែកនយោបាយ គឺជាសង្គ្រាមត្រជាក់» («La politique est une guerre non violente... La guerre, c'est une politique sanglante») ។ គួរសង្កេតមើលថា នៅលើឆាកកម្ពុជាសព្វថ្ងៃ ឬកខ្មែរក្រហមបានឈ្នះទាំង «នយោបាយក្តៅ» និងឈ្នះទាំង«សង្គ្រាមត្រជាក់»... ចំណែកយួនវិញបានត្រូវចាញ់គ្រប់ជ្រុងជ្រោយ និងគ្រប់ច្រកផ្លូវ ។ ដូច្នេះ យើងត្រូវមើលថា ហ៊ុន-សែនមានក្រឡាជាខ្មែរក្រហម (ចិន) ហើយគឺស្តេចសីហនុទៅវិញទេ ដែលមានក្រឡាជា«យួន» ។ បើយើងមើលក្រឡាបែបដូចនេះមិនឃើញទេ គឺមកពីយើងមានតែភ្នែក តែជាភ្នែកឥតប្រស្រី ! ។

យោងតាមសុភាសិតចិន ៖ «អ្នកឈ្នះធ្វើស្តេច... អ្នកចាញ់ធ្វើចោរ» ។ នៅគ្រប់បញ្ហាសង្គ្រាម អ្នកចាញ់ត្រូវគេកាត់ក្បាល, ត្រូវបាត់បង់កិត្តិយស និងផ្ទះសំបែង ត្រូវវិនាសខ្លួន... ចំណែកពួកចាញ់ដែលនៅកាន់មុខតំណែងនៅឡើយ នឹងក្លាយទៅជា «ចំណាប់ខ្មាំង» ។៚

❑ ❑

❑